# សូមស្វាគមន៍មកកាន់សន្និសីទ

ប្រធាន ថូម៉ាស អេស ម៉នសុន

*យើងមានបំណងប្រាថ្នាចង់ឱ្យសមាជិកកាន់តែច្រើន បានមានឱកាសចូលរួម ព្រះវិហារបរិសុទ្ធ ដោយមិនបាច់ធ្វើដំណើរផ្លូវដ៏ឆ្ងាយ ។*

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំសូមផ្ដល់ការស្វាគមន៍ចំពោះអ្នកទាំងអស់គ្នា នៅពេលយើងចាប់ផ្ដើម សន្និសីទទូទៅពាក់កណ្ដាលឆ្នាំលើកទី 179 នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ខ្ញុំមានអំណរគុណណាស់ចំពោះជំនាន់ដែលយើងរស់នៅ --- ជាជំនាន់មួយដែលមានបច្ចេកវិទ្យាជឿនលឿន ដើម្បីយើងអាចនិយាយទៅកាន់អ្នករាល់គ្នានៅទូទាំងពិភពលោកបាន ។ នៅពេលពួកអ្នកមានសិទ្ធិអំណាចទូទៅ និងអ្នកដឹកនាំជំនួយឈរនៅទីនេះក្នុងមជ្ឈមណ្ឌលសន្និសីទនៅទីក្រុងសលត៍ លេក នោះសម្លេងរបស់យើងនឹងឮទៅ ដល់អ្នករាល់គ្នាតាមមធ្យោបាយផ្សេងៗ ដូចជា វិទ្យុ ទូរទស្សន៍ ការបញ្ជូនតាមផ្កាយរណប និងអ៊ិនធើរណែតជាដើម ។ ថ្វីត្បិតតែយើងនឹងនិយាយទៅកាន់អ្នករាល់គ្នាជាភាសាអង់គ្លេសក្ដី តែអ្នករាល់គ្នានឹងស្ដាប់ឮយើង ជាភាសាផ្សេងៗដែលមានជាង 92 ភាសា ។

ចាប់តាំងពីយើងបានជួបគ្នាលើកមុននៅខែ មេសា ឆ្នាំនេះ យើងបានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធអូខឺម៉ោនចិនយូថាហ៍ដ៏ស្រស់ស្អាតនៅយ៉័រដាន់ប៉ែកខាងត្បូង រដ្ឋ យូថាហ៍ ។ នៅចន្លោះការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធដ្រាភឺយូថាហ៍ នៅខែ មិនា ហើយការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ អូខឺម៉ោនចិនយូថាហ៍ នាពេលថ្មីៗបំផុតនេះ នៅខែ សីហា មានព្រឹត្តការណ៍ខាងវប្បធម៌ចំនួនពីរយប់ដ៏អស្ចារ្យមួយដែលបានធ្វើឡើងជាលក្ខណៈយុវវ័យមកពីមណ្ឌលនៃព្រះវិហារបរិសុទ្ធទាំងពីរ ។ ផលិតកម្មជាច្រើនបានគូរឡើងវិញនូវកេរមរតកដ៏ច្រើននៃរដ្ឋយូថាហ៍ តាមរយៈចំរៀង និងការរាំ ។ យើងត្រូវបានប្រាប់ថាមានចំនួនយុវវ័យទាំងអស់ ប្រហែលជា 14,000 នាក់ ដែលបានចូលរួមនៅក្នុង រយៈពេលពីរយប់នោះ ។

យើងបន្តសាងសង់ព្រះវិហារបរិសុទ្ធ ។ យើងមានបំណងប្រាថ្នាចង់ឱ្យសមាជិកកាន់តែច្រើន បានមានឱកាសចូលរួម ព្រះវិហារបរិសុទ្ធ ដោយមិនបាច់ធ្វើដំណើរផ្លូវដ៏ឆ្ងាយ ។ នៅទូទាំងពិភពលោក មានសមាជិករបស់យើងចំនួន 83 ភាគរយដែលរស់នៅក្នុងចំងាយ 320 គីឡូម៉ែត្រពីព្រះវិហារបរិសុទ្ធ ។ ភាគរយនោះនឹងបន្តកើនឡើង នៅពេលយើងសាងសង់ព្រះវិហារបរិសុទ្ធថ្មីៗនៅជុំវិញ ពិភពលោក ។ នៅពេលបច្ចុប្បន្ន យើងមានព្រះវិហារបរិសុទ្ធ ចំនួន 130 កំពុងប្រើប្រាស់ ហើយមានចំនួន 16 ទៀត ដែលបាន ប្រកាស ឬស្ថិតនៅក្រោមការសាងសង់ ។ នៅព្រឹកនេះ ខ្ញុំរីករាយនឹងប្រកាសថា មានព្រះវិហារបរិសុទ្ធចំនួន 5 បន្ថែមទៀត ដែល មានទីតាំង និងនៅប៉ុន្មានខែ និងឆ្នាំខាងមុខនេះ នឹងត្រូវបានសាងសង់នៅក្នុងទីតាំងដូចតទៅ: ទីក្រុងព្រិកហាំ រដ្ឋយូថាហ៍ ទីក្រុង កុងសេបស្យុង ប្រទេសឈីលី ទីក្រុងហ្វ័រតាឡេហ្សា ប្រទេសប្រេស៊ីល ទីក្រុងហ្វតឡ័រដឺឌែល រដ្ឋហ្វ្លរីដា និង ទីក្រុងសាប៉ូរ៉ូ ប្រទេសជប៉ុន ។

ពិធីបរិសុទ្ធចំនួនរាប់លាន ត្រូវបានធ្វើឡើងជំនួសជីដូនជីតាជាទីស្រឡាញ់របស់យើងដែលបានស្លាប់ទៅ នៅក្នុងព្រះវិហារបរិសុទ្ធជារៀងរាល់ឆ្នាំ ។ សូមឱ្យយើងបន្តស្មោះត្រង់នៅក្នុងការធ្វើនូវពិធីបរិសុទ្ធបែបនេះសំរាប់អ្នកទាំងឡាយ ដែលមិនអាចធ្វើសំរាប់ខ្លួន

ពួកគេផ្ទាល់បាន។ ខ្ញុំស្រឡាញ់ប្រសាសន៍របស់ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ នៅពេលលោកបានលើកឡើងអំពីការបំរើក្នុងព្រះវិហារបរិសុទ្ធ និងអំពីពិភពវិញ្ញាណក្រោយពីជីវិតរមែងស្លាប់នេះ។ លោកមានប្រសាសន៍ថា: "តាមរយៈការខិតខំរបស់យើងជំនួសពួកគេ នោះច្រវាក់នៃទាសភាពរបស់ពួកគេ នឹងត្រូវបានរបូតចេញពីពួកគេ ហើយសេចក្ដីងងឹតដែលហ៊ុំព័ទ្ធជុំវិញពួកគេនឹងរលាយបាត់ទៅ ដើម្បីឱ្យពន្លឺអាចចែងចាំងមកលើពួកគេ ហើយពួកគេនឹង ស្ដាប់ឮក្នុងពិភពវិញ្ញាណអំពីកិច្ចការដែលបានធ្វើឡើងសំរាប់ពួកគេ តាមរយៈ[មនុស្ស]របស់ពួកគេនៅទីនេះ ហើយនឹងរីករាយជាមួយអ្នករាល់គ្នានៅក្នុងការធ្វើកាតព្វកិច្ចទាំងនេះរបស់អ្នក"។1

បងប្អូនប្រុសស្រីជាទីស្រឡាញ់ សាសនាចក្របន្តរីកចំរើន ដូចដែលវាបានមានចាប់តាំងពីបានរៀបចំឡើងអស់រយៈពេល 179 ឆ្នាំកន្លងមកនេះ។ វាកំពុងតែផ្លាស់ប្ដូរជីវិតរស់នៅរបស់មនុស្សកាន់តែច្រើនឡើងៗជារៀងរាល់ឆ្នាំ ហើយកំពុងតែផ្សព្វផ្សាយទៅទូទាំងផែនដី នៅពេលកម្លាំងរបស់អ្នកផ្សព្វផ្សាយសាសនាយើង ស្វែងរកអ្នកទាំងឡាយ ដែលកំពុងតែ ស្វែងរកសេចក្ដីពិតដែលមាននៅក្នុងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ យើងសូមអំពាវនាវឱ្យសមាជិកនៃ សាសនាចក្រ ទាំងអស់គ្នា ធ្វើជាមិត្តចំពោះអ្នកផ្លាស់ប្រែចិត្តថ្មី ឈោងទៅរកពួកគេ ឱបក្រសោបពួកគេដោយក្ដីស្រឡាញ់ ហើយជួយ ពួកគេឱ្យមានអារម្មណ៍កក់ក្ដៅ។

ខ្ញុំសុំឱ្យសេចក្ដីជំនឿ និងការអធិស្ឋានរបស់អ្នក បន្តធ្វើឡើង សំរាប់តំបន់ទាំងឡាយដែលឥទ្ធិពលរបស់យើង មិនអាចទៅដល់និងជាកន្លែងដែលមិនអនុញ្ញាតឱ្យចែកចាយដំណឹងល្អដោយសេរីនៅពេលនេះ។ អព្ភូតហេតុជាច្រើន អាចកើតឡើងនៅពេលយើងធ្វើការណ៍នេះ។

បងប្អូនប្រុសស្រីរបស់ខ្ញុំ ឥឡូវនេះយើងមានចិត្តរំភើបដើម្បីស្ដាប់សារលិខិតទាំងឡាយ ដែលនឹងផ្ដល់មកឱ្យយើងនៅក្នុងរយៈពេលពីរថ្ងៃនេះ។ អ្នកទាំងឡាយដែលនឹងនិយាយមកកាន់យើង បានស្វែងរកជំនួយ និងការដឹកនាំមកពីស្ថានសួគ៌ នៅពេលពួកគេរៀបចំសារលិខិតរបស់ពួកគេ។ ពួកគេបានទទួលចំណាប់អារម្មណ៍អំពីអ្វីដែលពួកគេនឹងចែកចាយ ជាមួយយើង។ ដើម្បីឱ្យយើងអាចត្រូវបានពោរពេញទៅដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ នៅពេលយើងស្ដាប់ និងរៀន នេះគឺជាការអធិស្ឋានរបស់ខ្ញុំ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. Joseph F. Smith នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1916 ទំព័រ 6។

# ដើម្បីទទួលបានការណែនាំខាងវិញ្ញាណ

អែលឌើរឆាដ ជី ស្កត
នៃក្រុមនៃពួកសាវកដប់ពីរនាក់

*តាមរយៈការអនុវត្តន៍ដោយយកចិត្តទុកដាក់ តាមរយៈការអនុវត្តន៍គោលការណ៍ត្រឹមត្រូវ និងតាមរយៈការឆាប់ដឹងចំពោះអារម្មណ៍ដែលកើតមាន នោះអ្នកនឹងទទួលបានការដឹកនាំខាងវិញ្ញាណ ។*

នៅក្នុងប្រវត្តិសាស្ត្រ មានមនុស្សជាច្រើនបានទទួលការណែនាំជាជំនួយក្នុងការដោះស្រាយបញ្ហាទាំងឡាយនៅក្នុងជីវិតរស់នៅរបស់ពួកគេ តាមរយៈការធ្វើតាមគំរូរបស់បុគ្គលជាក់លាក់ ដែលបានដោះស្រាយបញ្ហាស្រដៀងគ្នានោះ ។ នៅសព្វថ្ងៃនេះ ស្ថានភាពពិភពលោកផ្លាស់ប្ដូរយ៉ាងខ្លាំង ដែលធ្វើឱ្យសកម្មភាពដូច្នោះ ជារឿយៗមិនកើតមានសំរាប់យើង ។

ខ្លួនខ្ញុំផ្ទាល់រីករាយនៅក្នុងភាពពិតនោះ ដោយសារវាបង្កើតជាលក្ខខណ្ឌមួយ ដែលចាំបាច់ឱ្យយើងកាន់តែពឹងផ្អែកទៅលើព្រះវិញ្ញាណ ដើម្បីដឹកនាំយើងនៅក្នុងការផ្លាស់ប្ដូរដំណាក់កាលនៃជីវិត ។ ហេតុដូច្នេះ យើងត្រូវបានដឹកនាំឱ្យស្វែងរកការបំផុសគំនិតផ្ទាល់ខ្លួន នៅក្នុងការធ្វើការសម្រេចចិត្តសំខាន់ក្នុងជីវិត ។

តើអ្នកអាចធ្វើបានអ្វីខ្លះ ដើម្បីបង្កើនសមត្ថភាពរបស់អ្នក ដើម្បីត្រូវបានដឹកនាំឱ្យធ្វើការសម្រេចចិត្តត្រឹមត្រូវ នៅក្នុងជីវិតរបស់អ្នក? តើគោលការណ៍អ្វីខ្លះ ដែលការទំនាក់ទំនងខាងវិញ្ញាណពឹងអាស្រ័យនោះ? តើឧបសគ្គចំបងៗ ចំពោះទំនាក់ទំនងនោះ ដែលអ្នកចាំបាច់ត្រូវជៀសវាងមានអ្វីខ្លះ?

ប្រធាន យ៉ូហាន ថេលើរ បានសរសេរថា : "កាលពីជាងសែសិបឆ្នាំមុន យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍មកកាន់ខ្ញុំថា : 'បងប្រុស ថេលើរ បងបានទទួលព្រះវិញ្ញាណបរិសុទ្ធហើយ ឥឡូវនេះសូមធ្វើតាមព្រះចេស្ដានៃព្រះវិញ្ញានោះចុះ ហើយព្រះវិញ្ញាណនោះនឹងដឹកនាំបងទៅក្នុងរាល់សេចក្ដីពិត បន្ដិចម្ដងៗ រហូតដល់គោលការណ៍នៃវិវរណៈកើតមានចំពោះបងប្រុស' ។ បន្ទាប់មក លោកបានប្រាប់ខ្ញុំថា នៅពេលក្រោកពីដំណេកខ្ញុំមិនត្រូវភ្លេចឱនក្បាលចំពោះព្រះអម្ចាស់ ហើយលះបង់ខ្លួនឯងចំពោះទ្រង់ពេញមួយថ្ងៃនោះឡើយ" ។1

ព្រះវរបិតាសួគ៌ជ្រាបថាអ្នកនឹងប្រឈមមុខនឹងឧបសគ្គ ហើយទាមទារឱ្យអ្នកធ្វើការសម្រេចចិត្តមួយចំនួន ដែលនឹងហួសពីសមត្ថភាព របស់អ្នកដើម្បីសម្រេចចិត្តដោយត្រឹមត្រូវ ។ នៅក្នុងផែនការនៃសុភមង្គលរបស់ទ្រង់ ទ្រង់បានដាក់វិត្ថុបម្រុងមួយសំរាប់អ្នក ដើម្បីទទួលជំនួយចំពោះឧបសគ្គ និងការសម្រេចចិត្តដូច្នេះ អំឡុងពេលជីវិតរមែងស្លាប់របស់អ្នក ។ ជំនួយនោះនឹងកើតមានចំពោះ អ្នកតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ជាការដឹកនាំខាងវិញ្ញាណ ។ វាគឺជាអំណាចមួយ ដែលហួសពីសមត្ថភាពផ្ទាល់ខ្លួនរបស់អ្នក ដែលព្រះវរបិតាសួគ៌ជាទីស្រឡាញ់សព្វព្រះទ័យឱ្យអ្នកប្រើប្រាស់ជាប្រចាំ សំរាប់សេចក្ដីសុខសាន្ត និងសុភមង្គលរបស់អ្នក ។

ខ្ញុំជឿថា គ្មានរូបមន្ត ឬបច្ចេកទេសសាមញ្ញណា ដែលនឹងអាចឱ្យអ្នកមានសមត្ថភាពពូកែ ដើម្បីត្រូវបានដឹកនាំដោយសម្លេងនៃព្រះវិញ្ញាណនោះទេ។ ព្រះវរបិតារបស់យើងរំពឹងឱ្យអ្នករៀនអំពីរបៀប ដើម្បីទទួលនូវជំនួយដ៏ទេវភាពនោះ តាមរយៈការអនុវត្តនៃសេចក្តីជំនឿទៅលើទ្រង់ និងព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ។ បើអ្នកទទួលបានការដឹកនាំដ៏បំផុសគំនិត ដោយគ្រាន់តែសុំ នោះអ្នកនឹងប្រែជាទន់ខ្សោយ ហើយកាន់តែពឹងផ្អែកទៅលើពួកទ្រង់។ ពួកទ្រង់ព្រះញាណថា ការរីកចំរើនផ្ទាល់ខ្លួនដ៏សំខាន់ នឹងកើតមាន នៅពេលអ្នកពុះពារដើម្បីរៀនអំពីរបៀបតាមការដឹកនាំដោយព្រះវិញ្ញាណ។ អ្វីដែលលេចឡើងជាតំបូងថាជាកិច្ចការគួរឱ្យតក់ស្លុត នឹងមានភាពកាន់តែងាយស្រួលដើម្បីគ្រប់គ្រងនាពេលក្រោយមក នៅពេលអ្នកព្យាយាមជាប្រចាំដើម្បីស្គាល់ និងធ្វើតាមអារម្មណ៍ដែលបានបំផុសគំនិតដោយព្រះវិញ្ញាណ។ ទំនុកចិត្តរបស់អ្នកទៅលើការដឹកនាំដែលអ្នកទទួលមកពីព្រះវិញ្ញាណបរិសុទ្ធនឹងមានកាន់តែខ្លាំងឡើងផងដែរ។ ខ្ញុំសូមធ្វើជាសាក្សីថា នៅពេលអ្នកទទួលបានបទពិសោធន៍ និងជោគជ័យនៅក្នុងការដឹកនាំដោយព្រះវិញ្ញាណ នោះទំនុកចិត្តរបស់អ្នកនៅក្នុងចំណាប់អារម្មណ៍ដែលអ្នកទទួល អាចប្រែជាមានភាពកាន់តែជាក់លាក់ជាងការពឹងអាស្រ័យរបស់អ្នកទៅលើអ្វីដែលអ្នកមើលឃើញ ឬស្តាប់ឮទៅទៀត។

ជីវភាពខាងវិញ្ញាណផ្តល់ផលផ្លែចំនួនពីរ។ ទីមួយគឺការបំផុសគំនិត ដើម្បីដឹងនូវអ្វីដែលត្រូវធ្វើ។ ទីពីរគឺជាអំណាច ឬសមត្ថភាពដើម្បីធ្វើអ្វីដែលអ្នកដឹងថាត្រូវធ្វើ។ សមត្ថភាពទាំងពីរនេះកើតឡើងព្រមគ្នា។ នោះជាមូលហេតុដែលនីហ្វៃអាចនិយាយថា " ខ្ញុំនឹងទៅ ហើយធ្វើនូវ"។ 2 គាត់ដឹងថាក្រិត្យវិន័យខាងវិញ្ញាណគឺពឹងផ្អែកទៅលើការបំផុសគំនិត និងអំណាច។ មែនហើយព្រះឆ្លើយតបការអធិស្ឋាន ហើយប្រទានដល់យើងនូវការដឹកនាំខាងវិញ្ញាណ នៅពេលយើងរស់នៅដោយ ការគោរពប្រតិបត្តិហើយអនុវត្តសេចក្តីជំនឿដែលតំរូវឱ្យមានទៅលើទ្រង់។

ឥឡូវនេះ ខ្ញុំចែកចាយបទពិសោធន៍មួយដែលបានបង្រៀនខ្ញុំអំពីរបៀបមួយ ដើម្បីទទួលបានការណែនាំខាងវិញ្ញាណ។ មានថ្ងៃអាទិត្យមួយ ខ្ញុំបានចូលរួមក្នុងការប្រជុំបព្វជិតភាពនៅសាខាភាសាអេស្ប៉ាញ នៅទីក្រុងម៉ិចស៊ិកូ។ ខ្ញុំនឹកចាំយ៉ាងច្បាស់អំពីអ្នកដឹកនាំបព្វជិតភាពជនជាតិម៉ិកស៊ិកូដ៏រាបសារម្នាក់ ដែលបានពុះពារក្នុងការទំនាក់ទំនង សេចក្តីពិតនៃដំណឹងល្អនៅក្នុងសៀវភៅមេរៀនរបស់គាត់។ ខ្ញុំបានកត់សំគាល់ឃើញនូវបំណងប្រាថ្នាដែលគាត់មាន ដើម្បីចែកចាយគោលការណ៍ទាំងឡាយដែលគាត់ឱ្យតម្លៃជាខ្លាំង ជាមួយនឹងសមាជិកក្រុមរបស់គាត់។ គាត់បានទទួលស្គាល់ថា គោលការណ៍ទាំងនោះមានតម្លៃខ្លាំងណាស់ចំពោះបងប្អូនប្រុសដែលមានវត្តមាននៅទីនោះ។ តាមអាកប្បកិរិយារបស់គាត់ បានបង្ហាញនូវភស្តុតាងនៃសេចក្តីស្រឡាញ់សុទ្ធសាធរបស់ព្រះអង្គសង្គ្រោះ និងសេចក្តីស្រឡាញ់ចំពោះអ្នកទាំងឡាយដែលគាត់បានបង្រៀន។

ភាពស្មោះត្រង់ បំណងប្រាថ្នាបរិសុទ្ធ និងសេចក្តីស្រឡាញ់របស់គាត់ បាននាំឱ្យមានកម្លាំងខាងវិញ្ញាណពេញនៅក្នុងបន្ទប់។ ខ្ញុំត្រូវបានប៉ះនឹងដួងចិត្តយ៉ាងខ្លាំង។ បន្ទាប់មក ខ្ញុំបានចាប់ផ្តើមទទួលចំណាប់អារម្មណ៍ផ្ទាល់ខ្លួន នៅពេល គ្រូបង្រៀនដ៏រាបសារនោះបន្តបង្រៀនគោលការណ៍ទាំងឡាយ។ វាគឺជារឿងផ្ទាល់ខ្លួន ហើយទាក់ទងទៅនឹងកិច្ចការរបស់ខ្ញុំនៅក្នុងតំបន់។ ចំណាប់អារម្មណ៍ទាំងនោះ ជាចម្លើយចំពោះការខិតខំរៀនសូត្រដ៏យូរអង្វែង និងប្រកបដោយការអធិស្ឋានរបស់ខ្ញុំ។

នៅពេលកើតមានចំណាប់អារម្មណ៍ម្តងៗ ខ្ញុំបានសរសេរវាទុកដោយយកចិត្តទុកដាក់។ នៅក្នុងដំណើរការនោះ ខ្ញុំត្រូវបានផ្តល់ឱ្យនូវសេចក្តីពិតដ៏មានតម្លៃ ដែលខ្ញុំត្រូវការយ៉ាងខ្លាំង ដើម្បីធ្វើជាអ្នកបំរើរបស់ព្រះអម្ចាស់ឱ្យកាន់តែ មានប្រសិទ្ធភាព។ រឿងលំអិតនៃទំនាក់ទំនងទាំងឡាយ គឺជារឿងពិសិដ្ឋ ហើយដូចជាពររបស់លោកអយ្យកោ សំរាប់ជាប្រយោជន៍ផ្ទាល់ខ្លួនរបស់ខ្ញុំដូច្នេះដែរ។ ខ្ញុំត្រូវបានផ្តល់ឱ្យនូវការដឹកនាំ ការណែនាំជាក់លាក់ ហើយជាការសន្យា ដែលមានលក្ខខណ្ឌ ដែលបានផ្លាស់ប្តូរទិសដៅនៃជីវិតរបស់ខ្ញុំប្រកបដោយគុណប្រយោជន៍។

ក្រោយមក ខ្ញុំបានទៅថ្នាក់សាលាថ្ងៃអាទិត្យនៅក្នុងវួដរបស់យើង ជាកន្លែងដែលគ្រូបង្រៀនដែលមានការអប់រំខ្ពស់ម្នាក់ បង្រៀនមេរៀនរបស់គាត់។ បទពិសោធន៍នោះ គឺមានការផ្ទុយគ្នាចំពោះមេរៀនមួយដែលខ្ញុំរីករាយនៅក្នុងការប្រជុំ បព្វជិតភាព។ ចំពោះខ្ញុំវាហាក់ដូចជាគ្រូបង្រៀន បានជ្រើសរើសសេចក្តីយោងពិបាកយល់ និងឧទាហរណ៍ចម្លែកៗ ដោយចេតនា មកបង្ហាញអំពីគោលការណ៍នៃមេរៀន។ ខ្ញុំមានចំណាប់អារម្មណ៍ផ្សេង ថាគ្រូបង្រៀននេះ កំពុងតែប្រើប្រាស់ឱកាសបង្រៀន ដើម្បីធ្វើឱ្យសិស្សក្នុងថ្នាក់ចាប់អារម្មណ៍ជាមួយនឹងចំណេះដឹងយ៉ាងច្រើនរបស់គាត់។ តាមការឱ្យតម្លៃ ជាក់ស្តែងណាស់ថា គាត់ហាក់ដូចជាគ្មានបំណងក្នុងការទំនាក់ទំនងគោលការណ៍ទាំងឡាយ ដូចជាអ្នកដឹកនាំបព្វជិតភាពរាបសារបានមានទេ។

នៅក្នុងបរិយាកាសនោះ ចំណាប់អារម្មណ៍ដ៏ខ្លាំង បានចាប់ផ្តើមហូរមកលើខ្ញុំម្តងទៀត។ ខ្ញុំបានសរសេរទុក។ សារលិខិតបានមាននូវដំបូន្មានជាក់លាក់អំពីរបៀបដើម្បីប្រែក្លាយជាឧបករណ៍មួយកាន់តែមានប្រសិទ្ធភាព នៅក្នុងព្រះហស្តព្រះអម្ចាស់។ ខ្ញុំបានទទួលអារម្មណ៍បែបនេះដែលមានលក្ខណៈផ្ទាល់ខ្លួនបំផុត រហូតដល់ខ្ញុំមានអារម្មណ៍ថា វាពុំមែនជារឿងសមរម្យឡើយ ដើម្បីកត់ត្រារឿងទាំងនោះនៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ។ ខ្ញុំបានស្វែងរកកន្លែងដែលស្ងាត់ ហើយខ្ញុំបានបន្តសរសេរអំពីអារម្មណ៍ដែលហូរមកក្នុងគំនិត និងដួងចិត្តរបស់ខ្ញុំ ដោយស្មោះត្រង់តាមដែលខ្ញុំអាចធ្វើទៅបាន។ បន្ទាប់ពីចំណាប់ អារម្មណ៍ដ៏មានអំណាចនីមួយៗ ត្រូវបានកត់ត្រាទុក ខ្ញុំបានពិចារណាអំពីអារម្មណ៍ដែលខ្ញុំបានទទួល ដើម្បីកំណត់ថាបើខ្ញុំបានសរសេរ ទុកត្រឹមត្រូវឬទេ។ ជាលទ្ធផលខ្ញុំបានធ្វើការផ្លាស់ប្តូរបន្តិចបន្តួចចំពោះអ្វីដែលបានសរសេរ។ បន្ទាប់មកខ្ញុំបានសិក្សាអំពីអត្ថន័យ និងការអនុវត្តន៍នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ខ្ញុំ។

បន្ទាប់មក ខ្ញុំបានអធិស្ឋាន រំឮកជាមួយនឹងព្រះអម្ចាស់អំពីអ្វីដែលខ្ញុំបានគិតថា ខ្ញុំត្រូវបានបង្រៀនដោយព្រះវិញ្ញាណ។ នៅពេលអារម្មណ៍នៃភាពសុខសាន្តមួយបានកើតឡើង ខ្ញុំបានអរគុណដល់ទ្រង់សំរាប់ការណែនាំដែលបានប្រទានឱ្យ។ ពេលនោះខ្ញុំបានទទួលអារម្មណ៍ឱ្យសួរ ថាតើ "មានអ្វីជាច្រើនទៀតដែលនឹងប្រទានឱ្យដែរឬទេ?" ខ្ញុំបានទទួលចំណាប់អារម្មណ៍បន្ថែម ហើយដំណើរការនៃការសរសេរ ទុកនូវ ចំណាប់អារម្មណ៍ ការពិចារណា និងការអធិស្ឋានសុំការបញ្ជាក់ត្រូវបានធ្វើសារជាថ្មី។ ជាថ្មីម្តងទៀតខ្ញុំបានបំផុសគំនិត ឱ្យសួរថា "តើមានអ្វីជាច្រើនទៀត ដែលខ្ញុំគួរតែដឹងឬទេ?" មាន។ នៅពេលដែលបទពិសោធន៍យូរអង្វែងនិងពិសិដ្ឋបំផុតនោះ ត្រូវបានបញ្ចប់ ខ្ញុំបានទទួលការដឹកនាំផ្ទាល់ខ្លួនដ៏ជាក់លាក់ ហើយមានតម្លៃបំផុតមួយចំនួន ដែលមនុស្សអាចសង្ឃឹមដើម្បីទទួលបាននៅក្នុងជីវិត នេះ។ បើខ្ញុំមិនឆ្លើយតបទៅនឹង ចំណាប់អារម្មណ៍ដំបូង ហើយកត់ត្រាវា ទុកទេនោះខ្ញុំនឹងមិនបានទទួលការណែនាំចុងក្រោយ និងមានតម្លៃបំផុតនោះដែរ។

អ្វីដែលខ្ញុំបានពិពណ៌នា គឺមិនមែនជាបទពិសោធន៍ដាច់ដោយឡែកពីគេនោះទេ។ វាជានិមិត្តរូបឱ្យគោលការណ៍ពិត មួយចំនួនស្តីអំពីការទំនាក់ទំនងមកពីព្រះអម្ចាស់ចំពោះកូនចៅរបស់ទ្រង់នៅលើផែនដីនេះ។ ខ្ញុំជឿថា អ្នកនឹងមិនអាចស្តាប់ឮការដឹកនាំផ្ទាល់ខ្លួន និងមានតម្លៃបំផុតមកពីព្រះវិញ្ញាណទេ បើសិនជាអ្នកមិនឆ្លើយតប កត់ត្រាទុក និងអនុវត្តការបំផុសគំនិតដំបូង ដែលកើតមានចំពោះអ្នកនោះ។

ចំណាប់អារម្មណ៍មកពីព្រះវិញ្ញាណ អាចកើតមានជាចម្លើយចំពោះការអធិស្ឋានជាបន្ទាន់ ឬ មិនចង់បាន នៅពេលត្រូវការ។ ពេលខ្លះ ព្រះអម្ចាស់បើកសម្តែងសេចក្តីពិតមកកាន់អ្នក នៅពេលអ្នកមិនស្វែងរកវាយ៉ាងសកម្ម ដូចជានៅពេលអ្នកកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ ហើយមិនដឹងអំពីវា។ ទោះជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់ នឹងមិនបង្ខំអ្នកឱ្យរៀនដែរ។ អ្នកត្រូវតែអនុវត្តសិទ្ធិសេរីភាពរបស់អ្នក ដើម្បីអនុញ្ញាតឱ្យព្រះវិញ្ញាណបង្រៀនដល់អ្នក។ នៅពេលអ្នកធ្វើការអនុវត្តន៍មួយនេះនៅក្នុងជីវិតរបស់អ្នក នោះអ្នកនឹងកាន់តែទទួលបានអារម្មណ៍ដែលកើតមានជាមួយ នឹងការដឹកនាំខាងវិញ្ញាណបន្ថែមទៀត។ បន្ទាប់មក នៅពេលការណែនាំនោះកើតមាន ពេលខ្លះនៅពេលដែលអ្នកមិនបាន រំពឹងទុក នោះអ្នកនឹងស្គាល់វាកាន់តែងាយស្រួលជាង។

ឥទ្ធិពលបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ អាចត្រូវបានលុប ឬបិទបាំងដោយអារម្មណ៍ខ្លាំងៗ ដូចជាកំហឹង ការស្អប់ តណ្ហា ភ័យខ្លាច ឬភាពឆ្មើងឆ្មៃ។ នៅពេលឥទ្ធិពលដូចនេះកើតមាន វាដូចជាយើងព្យាយាមញ៉ាំផ្លែទំពាំងបាយជូរយ៉ាងឆ្ងាញ់ ក្នុងពេលកំពុងញ៉ាំម្ទេសយ៉ាងហិលផងដែរ។ រសជាតិគឺមានទាំងពីរ ប៉ុន្តែរសជាតិមួយ វាលប់បំបាត់រសជាតិមួយទៀត។ ស្រដៀងគ្នានេះដែរ អារម្មណ៍ខ្លាំងៗត្រូវលប់បំបាត់ការបំផុសគំនិតដ៏ផ្អែមល្ហែមនៃព្រះវិញ្ញាណបរិសុទ្ធ។

អំពើបាបគឺមានភាពញៀន ធ្វើឱ្យចុះអន់ថយនៅក្នុងខ្លួន នាំមកនូវការពុករលួយផ្សេងទៀត ជាការសម្លាប់ជីវភាពខាងវិញ្ញាណ មនសិការ និងមូលហេតុធ្វើឱ្យជីវិតពិតមានភាពស្រពិចស្រពិល។ ដែលជាការបំផ្លិចបំផ្លាញដល់គំនិត រូបកាយ និងវិញ្ញាណអំពើបាបគឺជាសារធាតុដែលស៊ីបំផ្លាញជីវិតខាងវិញ្ញាណ។ ដោយគ្មានការទប់ស្កាត់ នោះវានឹងមានកម្លាំងកាន់តែខ្លាំងឡើង។ វាអាចយកឈ្នះបាន តាមរយៈការប្រែចិត្ត និងសេចក្តីសុចរិត។

ខ្ញុំសូមចែកចាយការព្រមានមួយ។ សាតាំងពូកែណាស់ខាងការរារាំងការទំនាក់ទំនងខាងវិញ្ញាណ ដោយការបបួលមនុស្សម្នាក់ៗតាមរយៈការល្បួង ដើម្បីល្មើសនឹងក្រិត្យវិន័យ ដែលទំនាក់ទំនងខាងវិញ្ញាណ ត្រូវបានស្ថាបនាឡើង។ វាអាចធ្វើឱ្យមនុស្សមួយចំនួនជឿថា ពួកគេមិនអាចទទួលបាននូវការដឹកនាំដូច្នេះ មកពីព្រះអម្ចាស់បាននោះទេ។

សាតាំងបានក្លាយជាមេជំនាញក្នុងការប្រើប្រាស់អំណាចឱ្យញៀននឹងរូបអាសគ្រាម ដើម្បីរារាំងសមត្ថភាពបុគ្គលម្នាក់ៗ ពីការដឹកនាំដោយព្រះវិញ្ញាណ។ ការវាយប្រហាររបស់រូបអាសគ្រាមនៅក្នុងទម្រង់កាចសាហាវ ធ្វើឱ្យវិនាស បំផ្លិចបំផ្លាញទាំងអស់ បានបណ្តាលឱ្យមានទុក្ខសោក ការរងទុក្ខ ឈឺចាប់យ៉ាងខ្លាំង និងមហន្តរាយដល់អាពាហ៍ពិពាហ៍។ វាគឺជាឥទ្ធិពលដ៏អាក្រក់បំផុតមួយនៅលើផែនដី។ មិនថាវាមានតាមរយៈទំព័រការបោះពុម្ពផ្សាយ កុន ទូរទស្សន៍ ការនិពន្ធអាសគ្រាម ការនិយាយពាក្យថោកទាបតាមទូរស័ព្ទ ឬអេក្រង់កុំព្យូទ័រផ្ទាល់ខ្លួនទេ រូបអាសគ្រាមគឺពោរពេញទៅដោយការបំផ្លាញយ៉ាងធ្ងន់ធ្ងរ និងធ្វើឱ្យញៀន។

ឧបករណ៍ដ៏មានអំណាចរបស់លូស៊ីហ្វើរនេះ បង្ខូចដល់គំនិត និងដួងចិត្ត និងព្រលឹងរបស់មនុស្សគ្រប់រូបដែលប្រើប្រាស់វា។ មនុស្សទាំងអស់ដែលត្រូវបានជាប់នៅក្នុងសំណាញ់ ប្រឡោមចិត្ត និងបញ្ឆោតចិត្តរបស់រូបអាសគ្រាម ហើយស្ថិតនៅជាប់ក្នុងទីនោះនឹងក្លាយទៅជាញៀនចំពោះ ឥទ្ធិពលបំផ្លិចបំផ្លាញ និងអសីលធម៌របស់វា។ ត្បិតមានមនុស្សជាច្រើន ដែលញៀនមិនអាចយកឈ្នះដោយគ្មានជំនួយ បាននោះទេ។ គំរូប្រកបដោយទុក្ខភ័យគឺមានលក្ខណៈស្រដៀងគ្នាខ្លាំងណាស់។ វាចាប់ផ្ដើមជាមួយនឹងការចង់ដឹងចង់ឃើញ ដែលត្រូវបានផ្ដល់ឱ្យដោយការលើកទឹកចិត្ត និងត្រូវបានធ្វើឱ្យឃើញថាត្រូវ តាមរយៈការសន្មត់ដំបូងថា នៅពេលមើលដោយសំងាត់ នោះវាមិនគ្រោះថ្នាក់ដល់នរណាម្នាក់ទេ។ ត្បិតអស់អ្នកដែលត្រូវបានបំពេរដោយការកុហកនេះ នោះការ-ពិសោធន៍កើតមានកាន់តែខ្លាំងឡើង ដោយមានការលើកទឹកចិត្តកាន់តែខ្លាំង រហូតដល់ជាប់អន្ទាក់យ៉ាងជិតក្នុងទម្លាប់ញៀនអសីលធម៌យ៉ាងអាក្រក់ ដែលអនុវត្តការគ្រប់គ្រងយ៉ាងសាហាវរបស់វា។

ការចូលរួមនៅក្នុងរូបអាសគ្រាមនៅគ្រប់ទម្រង់អាក្រក់របស់វា គឺជាការបង្ហាញអំពីភាពអត្តានិយមដែល មិនអាចគ្រប់គ្រងបាន។ តើបុរសម្នាក់ ជាពិសេសអ្នកកាន់បព្វជិតភាព អាចមិនគិតអំពីការបំផ្លាញខាងអារម្មណ៍ និងវិញ្ញាណរបស់ស្ត្រី ជាពិសេសភរិយារបស់គាត់ ដោយសារសកម្មភាពគួរឱ្យស្អប់ខ្ពើមដូច្នេះតាមរបៀបណា?

នីហ្វៃបានប្រកាសដោយបំផុសគំនិតយ៉ាងល្អថា "ហើយ [អារក្ស] និងបង្ក្រាបឱ្យសុខ ហើយបំពេរពួកគេឱ្យបានសុខខាងរូបកាយ... ហើយ [វា] បានបញ្ឆោតព្រលឹងពួកគេដូច្នោះហើយ ហើយនាំពួកគេដោយប្រុងប្រយ័ត្នចុះទៅស្ថាននរក"។3

បើសិនជាអ្នកត្រូវបានជាប់អន្ទាក់នៅក្នុងរូបអាសគ្រាម ចូរធ្វើការតាំងចិត្តទាំងស្រុងមួយដើម្បីយកឈ្នះវា នៅពេលឥឡូវនេះ។ ចូរស្វែងរកកន្លែងស្ងប់ស្ងាត់មួយ អធិស្ឋានសុំជំនួយ និងការគាំទ្រជាបន្ទាន់។ ចូរអត់ធ្មត់ និងគោរពប្រតិបត្តិ។ ចូរកុំចុះចាញ់ឡើយ។

ឪពុកម្ដាយ ចូរដឹងថា ការញៀននឹងរូបអាសគ្រាម អាចចាប់ផ្ដើមជាមួយនឹងយុវវ័យតាំងពីនៅក្មេង។ ចូរចាត់វិធានការណ៍ការពារដើម្បីជៀសវាងពីសោកនាដកម្មនោះ។ ប្រធានស្តេក និងប៊ីស្សពទាំងឡាយ ចូរព្រមានអំពីសេចក្ដីអាក្រក់នេះ។ ចូរអញ្ជើញមនុស្សគ្រប់រូបដែលអ្នកគិតថាត្រូវបានជាប់ចំណងដោយរឿងនេះ ឱ្យមករកអ្នកដើម្បីជាជំនួយ។

បុគ្គលម្នាក់ដែលមានបទដ្ឋានរឹងមាំ និងការតាំងចិត្តស៊ូទ្រាំ ដើម្បីគោរពតាមបទដ្ឋានទាំងនោះនឹងពុំងាយដឹកនាំឱ្យធ្លាក់ទៅក្នុងភាពវិនាសបានឡើយ។ បុគ្គលម្នាក់ដែលត្រូវបានរុញច្រានយ៉ាងខ្លាំងដោយអំពើបាបដ៏ធំ និងអ្នកដែលអនុវត្តការគ្រប់គ្រងខ្លួនឯងនៅក្រៅពីឥទ្ធិពលរបស់មនុស្សមានទូវលក្ខណៈពិត។ ការប្រែចិត្ត គឺជាកិច្ចការដ៏មានប្រសិទ្ធភាពបំផុតសំរាប់មនុស្សប្រភេទនេះ។ អារម្មណ៍សោកស្ដាយ បន្ទាប់ពីបានធ្វើកំហុសមួយ គឺជាដីដែលមានជីវជាតិ ដែលអាចធ្វើឱ្យការប្រែចិត្តកើតចេញជាផ្លែផ្កាបាន។

ចូរមានការអត់ធ្មត់ នៅពេលអ្នកកំពុងតែធ្វើឱ្យលទ្ធភាពរបស់អ្នកបានល្អឥតខ្ចោះ ដើម្បីត្រូវបានដឹកនាំដោយព្រះវិញ្ញាណ។ តាមរយៈការអនុវត្តន៍ដោយយកចិត្តទុកដាក់ តាមរយៈការអនុវត្តន៍គោលការណ៍ត្រឹមត្រូវ និងតាមរយៈការឆាប់ដឹងចំពោះអារម្មណ៍ដែលកើតមាន នោះអ្នកនឹងទទួលបានការដឹកនាំខាងវិញ្ញាណ។ ខ្ញុំសូមថ្លែងជាសាក្សីថា ព្រះអម្ចាស់អាចមានបន្ទូលមកកាន់គំនិត និងដួងចិត្តរបស់យើង តាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ ពេលខ្លះ ចំណាប់អារម្មណ៍ គ្រាន់តែជាអារម្មណ៍ជាទូទៅប៉ុណ្ណោះ។

ពេលខ្លះ ការដឹកនាំកើតមកយ៉ាងច្បាស់លាស់ ហើយមិនខុសឆ្គងទេ ដើម្បីវាអាចត្រូវបានសរសេរទុកដូចជាការសរសេរតាមសូត្រខាងវិញ្ញាណដែរ ។ 4

ខ្ញុំសូមថ្លែងជាសាក្សីដ៏ឧឡារិកថា នៅពេលអ្នកអធិស្ឋានដោយអស់ពីព្រលឹងរបស់អ្នក ដោយភាពរាបសារ និងការដឹងគុណ នោះអ្នកអាចរៀនដើម្បីត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធយ៉ាងខ្ជាប់ខ្ជួន នៅក្នុងសេចក្ដីរំពឹងទុកនៃជីវិតទាំងអស់របស់អ្នក ។ ខ្ញុំបាន បញ្ជាក់ពីសេចក្ដីពិតពេញលេញនៃគោលការណ៍នោះ នៅក្នុងការសាកល្បងនៃជីវិតរបស់ខ្ញុំផ្ទាល់ ។ ខ្ញុំសូមធ្វើទីបន្ទាល់ថា អ្នកអាច រៀនគោលការណ៍ទាំងឡាយដើម្បីត្រូវបានដឹកនាំដោយព្រះវិញ្ញាណដោយខ្លួនឯងបាន ។ តាមរបៀបនោះ ព្រះអង្គសង្គ្រោះអាចដឹកនាំអ្នកឱ្យដោះស្រាយបញ្ហាទាំងឡាយ ហើយរីករាយនឹងសេចក្ដីសុខសាន្ត និងសុភមង្គលដ៏មហិមានៅក្នុងជីវិត នៅក្នុងព្រះនាម នៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. John Taylor, *The Gospel Kingdom* រៀបរៀងដោយ G. Homer Durham ( ឆ្នាំ 1943 ) ទំព័រ 43--44 ។
2. នីហ្វៃទី 1 3:7 ។
3. នីហ្វៃទី 2 28:21 ។
4. សូមមើល គ. និង ស. 8:2 ។